**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
**លេខាធិការដ្ឋាន**
លេខ ៥៤៧.១១៨ /គ.ជ.អ.ប

រាជធានីភ្នំពេញ, ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១១.

## គោរពជូន
## ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជា
## ប្រធានគ.ជ.អ.ប

**កម្មវត្ថុ:** របាយការណ៍លទ្ធផលកិច្ចប្រជុំថ្នាក់ជាតិ ស្តីពីវិមជ្ឈការមុខងារស្នូលរបស់គណៈកម្មការទន្លេមេគង្គ។

**យោង:** លិខិតលេខ១៩១៤ គ.ជ.ទ.ម.ក ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១ របស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា

តបតាមការអញ្ជើញរបស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា រូបខ្ញុំបាទដែលជាសមាជិកគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ប្រចាំនៅក្រសួងមហាផ្ទៃ និងមន្ត្រីថ្នាក់នាយកដ្ឋានមួយរូបបានទៅចូលរួមកិច្ចប្រជុំថ្នាក់ជាតិ ស្តីពីវិមជ្ឈការមុខងារស្នូលរបស់គណៈកម្មការទន្លេមេគង្គនៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១១ នៅសណ្ឋាគារសាន់វេ ក្រោមអធិបតីភាពរបស់ឯកឧត្តម លឹម គានហោ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងជាប្រធានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ដែលមានសមាជិកចូលរួមសរុបប្រហែល ៦០រូបមកពីក្រសួង និងស្ថាប័នពាក់ព័ន្ធផ្សេងៗ។

**គោលបំណង**

នេះជាកិច្ចប្រជុំថ្នាក់ជាតិលើកដំបូងរបស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជាដែលមានគោលបំណង (១) ជូនដំណឹងដល់ក្រសួង ស្ថាប័នពាក់ព័ន្ធពីវិមជ្ឈការមុខងារស្នូលរបស់គណៈកម្មការទន្លេមេគង្គ (២)គូសបញ្ជាក់ពីការចាត់ចែងស្ថាប័នជាតិ និងយន្តការសម្របសម្រួលអន្តរក្រសួង ដែលចាំបាច់សម្រាប់រៀបចំផែនទីបង្ហាញផ្លូវនៅថ្នាក់ ជាតិ និងទំនាក់ទំនងនៃការរៀបចំការងារនេះនៅថ្នាក់ជាតិ និងថ្នាក់តំបន់(៣) កំណត់អត្តសញ្ញាណលំអិតពីនីតិវិធីថ្នាក់ជាតិសម្រាប់អនុម័តលើផែនទីបង្ហាញផ្លូវ និង (៤) កំណត់បញ្ហាសំខាន់ៗតាមស្ថានភាពជាក់ស្តែងតាមប្រទេស ដែលត្រូវពិចារណានៅពេលរៀបចំផែនទីបង្ហាញផ្លូវ

## សាវតារ

គណៈកម្មការទន្លេមេគង្គ គឺជាអង្គការអាងទន្លេអន្តររដ្ឋាភិបាលមួយដែលបានបង្កើតឡើង នៅថ្ងៃទី ០៥ ខែមេសា ឆ្នាំ១៩៩៥ ដោយមានការចុះហត្ថលេខាលើកិច្ចព្រមព្រៀងសហប្រតិបត្តិការសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពនៅក្នុងអាងទន្លេមេគង្គ។ មូលហេតុចំបងដែលតម្រូវអោយមានការធ្វើវិមជ្ឈការមុខងារពីលេខាធិការដ្ឋានតំបន់មកប្រទេសជាសមាជិក គឺដោយសារស្ថានភាពសេដ្ឋកិច្ចនៃប្រទេសជា សមាជិកមានការរីកចម្រើនយ៉ាងខ្លាំង ដែលនាំអោយមានការកាត់បន្ថយការគាំទ្រ ពីដៃគូអភិវឌ្ឍន៍ជាបណ្តើរៗនឹងឈានទៅបញ្ចប់ទាំងស្រុងនៅមុនឆ្នាំ២០៣០។ កិច្ចប្រជុំកំពូលលើកដំបូងនៃគណៈកម្មការទន្លេមេគង្គ បានប្រព្រឹត្តទៅនៅខែ មេសា ឆ្នាំ២០១០ ហើយបានឯកភាពគ្នាលើចក្ខុវិស័យជាយុទ្ធសាស្ត្រដូចខាងក្រោម៖

- គណៈកម្មការទន្លេមេគង្គត្រូវធានាអោយមាននិរន្តរភាពខាងហិរញ្ញវត្ថុពីសំណាក់ប្រទេសជាសមាជិកចាប់ផ្តើមពីឆ្នាំ២០៣០
- ស្វែងយល់ពីបទពិសោធន៍នៃការអនុវត្តតាមបែបវិមជ្ឈការនូវមុខងារស្នូលរបស់គណៈកម្មការទន្លេមេគង្គលើការគ្រប់គ្រងអាងទន្លេនៃផែនការយុទ្ធសាស្ត្រ ២០១១-២០១៥
- រៀបចំផែនទីបង្ហាញផ្លូវសម្រាប់វិមជ្ឈការមុខងារស្នូល។

## ដំណើរការកិច្ចប្រជុំ

កិច្ចប្រជុំបានដំណើរការតាមរបៀបវារៈដូចដែលបានគ្រោងទុក ហើយបានពិភាក្សា យ៉ាងផុសផុលលើប្រធានបទ ដូចខាងក្រោម៖

១. ការចាត់ចែងស្ថាប័នអនុវត្ត និងការងារថ្នាក់ជាតិសម្រាប់ដំណើរការរៀបចំផែនទីបង្ហាញផ្លូវសម្រាប់ការអនុវត្តវិមជ្ឈការមុខងារស្នូល។ ពាក់ព័ន្ធនឹងប្រធានបទនេះគឺប្រទេសជាសមាជិកត្រូវបង្កើតក្រុមការងារអន្តរក្រសួងដើម្បីសម្រួលដល់ការអនុវត្តវិមជ្ឈការមុខងារស្នូល ដែលបានផ្ទេរមកប្រទេសនីមួយៗ។ ពាក់ព័ន្ធនឹងចំណុចនេះ អង្គប្រជុំបានឯកភាពលើយន្តការដែលមានស្រាប់គឺគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ដោយគ្រាន់តែត្រូវតែងតាំងជនបង្គោលថ្នាក់នាយកដ្ឋានជាកំរិតបច្ចេកទេសពីស្ថាប័នដែលជាសមាជិកគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ប៉ុន្តែមិនត្រូវយកសមាសភាពពីគ្រប់ក្រសួងទេ យកតែក្រសួងណាដែលការងាររបស់ខ្លួនមានលក្ខណៈបច្ចេកទេសសមស្រប និងអន្តរវិស័យ។

២. ការចាត់ចែងស្ថាប័នអនុវត្ត និងអនុម័តផែនទីបង្ហាញផ្លូវសម្រាប់ការអនុវត្តវិមជ្ឈការមុខងារស្ទូល។ អង្គប្រជុំបានឯកភាពផ្តល់អំណាចដល់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជាជាអ្នកអនុម័តផែនទីបង្ហាញផ្លូវផែនទីមុខងារនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមឧបនាយករដ្ឋមន្ត្រីមេត្តាជ្រាបជាសេចក្តីរាយការណ៍ និងមានមតិដឹកនាំដ៏ខ្ពង់ខ្ពស់។

សូមឯកឧត្តមមេត្តាទទួលនូវគារវកិច្ចគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំ។

**ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប**

**សក់_សេដ្ឋា**